# ការយាងត្រឡប់មកវិញរបស់

# ព្រះយេស៊ូវ

# និងការជំនុំជម្រះ

គោលជំនឿ៖ ផ្នែកទីប្រាំមួយ

សាឡូមភ្នំពេញ

# ការយាងត្រឡប់មកវិញរបស់ព្រះយេស៊ូវគ្រីស្ទ

*យើងខ្ញុំជឿថា ព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់ ទ្រង់នឹងយាងមកផែនដីវិញ ជារូបអង្គប្រកបដោយសិរីល្អតេជានុភាព និងឫទ្ធានុភាពដែលមនុស្សគ្រប់រូបអាចនឹងមើលឃើញដោយប្រចក្សនឹងភ្នែក។ ទ្រង់នឹងជំនុំជម្រះមនុស្សទាំងអស់ ទាំងមនុស្សរស់ ទាំងមនុស្សស្លាប់។*

អស់អ្នកណាដែលមានឈ្មោះក្នុងបញ្ជីជីវិត នោះពួកគេនឹង
បានរស់នៅជាមួយនឹងព្រះជាម្ចាស់ ប៉ុន្តែ អស់អ្នកណាដែល
មិនមានឈ្មោះកត់ទុកក្នុងបញ្ជីជីវិតទេ នោះព្រះជាម្ចាស់នឹង
បោះពួកគេចូលទៅក្នុងស្ថាននរកជាមួយនឹងអារក្សសាតាំង
ព្រមទាំងពួកពលបរិវារបស់វាផង ដែលកន្លែងនោះជាកន្លែង
វេទនាដ៏នៅអស់កល្បជានិច្ច។

# យើងខ្ញុំជឿថា ព្រះយេស៊ូវគ្រីស្ទជា ព្រះអម្ចាស់ ទ្រង់នឹងយាង មកផែនដីវិញ

# ១) យ៉ូហាន ១៤:៣ ទំព័រ ១៣៨៩

បើខ្ញុំទៅរៀបកន្លែងឲ្យអ្នករាល់គ្នា នោះខ្ញុំនឹងត្រឡប់មកវិញ នឹងទទួលអ្នករាល់គ្នាទៅឯខ្ញុំ ប្រយោជន៍ឲ្យអ្នករាល់គ្នាបាននៅកន្លែងដែលខ្ញុំនៅនោះដែរ

# ២) កិច្ចការ ១:១១ ទំព័រ ១៨០២

ពួកអ្នកស្រុកកាលីឡេអើយ ហេតុអ្វីបានជាឈរងើយមើលទៅលើមេឃដូច្នេះ ព្រះយេស៊ូវនេះឯង ដែលព្រះបានលើកពីអ្នករាល់គ្នា ឡើងទៅលើស្ថានសួគ៌ ទ្រង់នឹងយាងមកវិញ តាមបែបដដែលដូចជាអ្នករាល់គ្នាបានឃើញទ្រង់ទៅនោះដែរ

# ៣ ) ២យ៉ូហាន ៧ ទំព័រ ១៥៩១

ពីព្រោះមានអ្នកប្រវ័ញ្ចបញ្ឆោតជាច្រើនបានមកក្នុងលោកីយ ហើយ ជាពួកអ្នកដែលមិនព្រមទទួលថា ព្រះយេស៊ូវគ្រីស្ទបានមកក្នុងសាច់ឈាមទេ នោះហើយជាអ្នកប្រវ័ញ្ចបញ្ឆោត ហើយជាអ្នកទទឹងនឹងព្រះគ្រីស្ទផង

ជារូបអង្គប្រកបដោយសិរីល្អ តែជានុភាព និងឫទ្ធានុភាពដែលមនុស្សគ្រប់រូបអាចនឹងមើលឃើញដោយប្រចក្សនឹងភ្នែក។

# ៤) ម៉ាថាយ ២៤:៣០–៣១ ទំព័រ ១២៧៧

៣០នោះទីសំគាល់របស់កូនមនុស្សនឹងលេចមកនៅលើមេឃ គ្រប់ទាំងពូជមនុស្សនៅផែនដីនឹងគក់ទ្រូងយំ ក៏នឹងឃើញកូនមនុស្ស មកលើពពកនៅលើមេឃ មានទាំងព្រះចេស្តា នឹងសិរីល្អជាខ្លាំង

# ៤) ម៉ាថាយ ២៤:៣០–៣១ ទំព័រ ១២៧៧

៣១ហើយលោកនឹងចាត់ពួកទេវតារបស់លោក ឲ្យមកដោយ
សូរផ្លុំត្រែជាខ្លាំង ទេវតាទាំងនោះនឹងប្រមូលពួករើសតាំងរបស់
លោកពីទិសទាំង៤ ចាប់តាំងពីជើងមេឃម្ខាង រហូតដល់ជើង
មេឃម្ខាង។

ទ្រង់នឹងជំនុំជម្រះមនុស្សទាំងអស់ ទាំងមនុស្សរស់ ទាំងមនុស្សស្លាប់។

# ៥) ២ធីម៉ូថេ ៤:១ ទំព័រ ១៥៤៧

ដូច្នេះ ខ្ញុំផ្ដាំមកអ្នកយ៉ាងអស់ពីចិត្ត នៅចំពោះព្រះនឹងព្រះគ្រីស្ទយេស៊ូវ ដែលទ្រង់រៀបនឹងជំនុំជំរះ ទាំងមនុស្សរស់ នឹងមនុស្សស្លាប់ផង គឺផ្ដាំដោយអាងដំណើរទ្រង់យាងមក នឹងនគរទ្រង់...

អស់អ្នកណាដែលមានឈ្មោះក្នុងបញ្ជីជីវិត នោះពួកគេនឹង
បានរស់នៅជាមួយនឹងព្រះជាម្ចាស់ ប៉ុន្តែ អស់អ្នកណាដែល
មិនមានឈ្មោះកត់ទុកក្នុងបញ្ជីជីវិតទេ នោះព្រះជាម្ចាស់នឹង
បោះពួកគេចូលទៅក្នុងស្ថាននរកជាមួយនឹងអារក្សសាតាំង
ព្រមទាំងពួកពលបរិវារបស់វាផង ដែលកន្លែងនោះជាកន្លែង
វេទនាដ៏នៅអស់កល្បជានិច្ច។

# ៦) វិវរណៈ ២០:១០, ១៤-១៥ ទំព័រ ១៦១៤

១០រួចអារក្សដែលនាំគេឲ្យវង្វេង បានត្រូវបោះទៅក្នុងបឹង ដែលឆេះជាភ្លើង នឹងស្ពាន់ធ័រ ជាកន្លែងដែលសត្វនោះ នឹងហោរាក្លែងក្លាយនៅហើយ នោះវារាល់គ្នាត្រូវរងទុក្ខវេទនាទាំងយប់ទាំងថ្ងៃ នៅអស់កល្បជានិច្ចរៀងរាបតទៅ ។

# ៦) វិវរណៈ ២០:១០, ១៤-១៥ ទំព័រ ១៦១៤

១៤ចំណែកសេចក្ដីស្លាប់ នឹងស្ថានឃុំព្រលឹងមនុស្សស្លាប់ នោះត្រូវបោះទៅក្នុងបឹងភ្លើងដែរ នេះជាសេចក្ដីស្លាប់ទី២ ១៥បើអ្នកណាគ្មានឈ្មោះកត់ទុកក្នុងបញ្ជីជីវិត អ្នកនោះត្រូវបោះទៅក្នុងបឹងភ្លើង ។

# ៧) ម៉ាថាយ ២៥:៤១, ៤៦ ទំព័រ ១២៧៩

៤១រួចទ្រង់នឹងមានបន្ទូលទៅពួកខាងឆ្វេងទៀតថា ពួកអ្នករាល់គ្នាដែលត្រូវបណ្តាសាអើយ ចូរថយពីអញចេញទៅក្នុងភ្លើងដែលឆេះអស់កល្បជានិច្ច ដែលបានរៀបចំទុកសំរាប់អារក្ស ហើយនឹងពួកទេវតារបស់វាវិញ....

# ៧) ម៉ាថាយ ២៥:៤១, ៤៦ ទំព័រ ១២៧៩

[៤៦]ឯពួកអ្នកទាំងនោះនឹងថយទៅ មានទោសអស់កល្បជានិច្ច
តែពួកសុចរិតនឹងចូលទៅក្នុងជីវិតដ៏នៅអស់កល្បជានិច្ចវិញ ។

# ៨) ម៉ាថាយ ១៣:៤៩–៥០ ទំព័រ ១២៦០

៤៩ដល់ទីបំផុតកល្ប នឹងបានដូចគ្នាដែរ គឺពួកទេវតានឹងចេញទៅញែកយកពួកទុច្ចរិតពីពួកសុចរិតចេញ ៥០ហើយនឹងបោះគេចោលទៅក្នុងគុកភ្លើង នៅទីនោះ គេនឹងយំ ហើយសង្កៀតធ្មេញ ។


ថ្ងៃយាងត្រឡប់មកវិញ
របស់ព្រះយេស៊ូវ
ត្រូវបានលាក់ ដើម្បីឲ្យយើង
ត្រូវប្រុងស្មារតី
— Augustine —


យើងនាំគ្នានិយាយ
តែពីការយាងមកវិញជា
លើកទីពីររបស់ព្រះយេស៊ូវ
ខណៈពេលដែលមនុស្សពាក់
កណ្ដាលពិភពលោកមិន
ដែលបានឮពីការយាងមក
លើកទីមួយ។
— Oswald J. Smith
គោលជំនឿ ផ្នែកទីប្រាំមួយ
សាឡូមភ្នំពេញ
http://shalomphnompenh.com




ថ្នាក់រៀន
សម្រាប់
សមាជិកថ្មី

03-06-16

បន្ទាប់ពីការថ្វាយបង្គំ


ថ្ងៃអាទិត្យនៃ
សមាជិកភាព
02-28-16


ព្រះវរបិតា
ព្រះរាជបុត្រា
ព្រះវិញ្ញាណបរិសុទ្ធ
ព្រះ
ជា
ជា
ជា
មិនមែន
មិនមែន
មិនមែន